# ឯកឧត្តម ចម ប្រសិទ្ធ នាកិច្ចប្រជុំទ្វេភាគី និងកិច្ចប្រជុំលើកទី១ នៃរដ្ឋមន្ត្រីសេដ្ឋកិច្ច កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១០

ស្របជាមួយនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២ ដែលប្រារព្ធធ្វើនៅទីក្រុងដាណាំង ប្រទេសវៀតណាម ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជាបានជួបប្រជុំទ្វេរភាគីរវាងកម្ពុជា-វៀតណាម និងកិច្ច ប្រជុំលើកទី១ ថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចនៃប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម នៅថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១០ ផងដែរ ។

នៅក្នុងជំនួបទ្វេភាគី ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជួបប្រជុំជាមួយ ឯកឧត្តម Vu Huy Hoang រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម ដើម្បីពិភាក្សាលើបញ្ហាជម្រុញពាណិជ្ជកម្មទ្វេ ភាគីឱ្យដល់កំរិត ២ ពាន់លានដុល្លា តាមការណែនាំរបស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងឯកឧត្តម Vu Huy Hoang បានឯកភាពគ្នាថានឹងបន្តសម្រួលដល់ការតាំងពិព័ណ៌ផ្សេងៗដែលធ្វើនៅកម្ពុជា និងនៅវៀតណាមនាពេលខាងមុខ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជំរុញឱ្យភាគីមិត្តវៀតណាម ពិនិត្យលទ្ធភាពចុះហត្ថលេខាលើលិខិតផ្តល់កូតាថ្នាំជក់ និងបង្កើនកូតាអង្ករឱ្យមកកម្ពុជាឱ្យបានឆាប់ ព្រោះសន្លឹកថ្នាំនៅកម្ពុជាកំពុងធ្លាក់ថ្លៃ ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាជនរស់នៅខេត្តកំពង់ចាម និងក្រចេះ។ ឯកឧត្តមរដ្ឋមន្ត្រីវៀតណាម យល់ព្រមបង្កើនកូតាអង្ករទៅដល់២៥០,000តោន សម្រាប់ ឆ្នាំ២០១០ សំដៅជួយដល់ការនាំចេញអង្ករដោយមិនជាប់ពន្ធទៅកាន់ វៀតណាម និងផ្តល់កូតាថ្នាំជក់ចំនួន៣000តោន ផងដែរ ដោយគ្រោងចុះហត្ថលេខាលើលិខិតផ្លាស់ប្តូរជាមួយគ្នា នៅពាក់កណ្តាល ខែកញ្ញាខាងមុខនេះ។ ជាមួយនោះ ឯកឧត្តមរដ្ឋមន្ត្រីវៀតណាមបាន ឯកភាព តាមសំណើររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងការជួយជំរុញការសាងសង់ទីផ្សារព្រំដែន នៅច្រកដា ខេត្តកំពង់ចាមក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីជំរុញការធ្វើពាណិជ្ជកម្មនៃប្រជាជនជាប់ព្រំដែនប្រទេសទាំងពីរ ហើយឯកឧត្តម រដ្ឋមន្ត្រីវៀតណាមបានយល់ព្រមមកចូលរួមសម្ពោធផ្សារនេះនៅពេលសាងសង់រួចផងដែរ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានឯកភាពជាមួយភាគីវៀតណាម ថានឹងចាត់ឱ្យមន្ត្រីជំនាញ សហការគ្នាសិក្សា និងរិះរកវិធានការណ៍សម្រាប់ទប់ទល់ជាមួយ ប្រទេសប្រេស៊ីល ដែលមានផែនការដាក់វិធានការណ៍ដាក់ពន្ធប្រឆាំង
នឹងការលក់បង្ខូចថ្លៃលើផលិតផលស្បែកជើងនាំចេញទៅពីបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួន ដែលអាចរួមមាន វៀតណាម និងកម្ពុជាផងដែរ ។

នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១០ ដដែលនេះក៏មានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចលើកទី១ នៃប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (CLMV) ផងដែរ ដែលកិច្ចប្រជុំបានផ្តោតការយកចិត្តទុកដាក់លើការអនុវត្តស្មារតីនៃសេចក្តីសម្រេចចិត្ត នៃថ្នាក់ដឹកនាំកំពូលលើកទី៤នៃប្រទេស CLMV ដែលបានបារព្ធធ្វើនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២00៨ នៅទីក្រុងហាណូយ និងគិតគូរពីកម្មវិធីអភិវឌ្ឍន៍រួមគ្នាសម្រាប់ការទាក់ទាញអ្នកវិនិយោគ និងពាណិជ្ជកម្មករពីវិស័យឯកជន ឱ្យបានកាន់តែច្រើនថែមទៀតនៅក្នុងប្រទេស CLMV។ កិច្ចប្រជុំក៏បានសម្រេចឱ្យមានការរៀបចំពិពណ៌ពាណិជ្ជកម្ម CLMV រៀងរាល់ឆ្នាំ, ខិតខំសម្របសម្រួលពាណិជ្ជកម្មតាមព្រំដែន តាមរយៈការសម្រួលបែបបទគយ ប្រយុទ្ធប្រឆាំងនឹងការធ្វើពាណិជ្ជកម្មខុសច្បាប់ និងការរត់ពន្ធ, ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងតំបន់កែច្នៃសម្រាប់ការនាំចេញ, ការពង្រីកវិស័យវិនិយោគឱ្យបានច្រើនសម្រាប់ប្រទេស

CLMV, ការជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ធនធានមនុស្ស, ការកាត់បន្ថយគំលាតអភិវឌ្ឍនៃប្រទេស CLMV នៅក្នុងអាស៊ាន, ការបង្កើននយោបាយសម្របសម្រួលរវាងប្រទេសCLMV ក្នុងតំបន់ និងវេទិកាអន្តរជាតិ ។

ជាមួយនោះ អង្គប្រជុំបានសម្រេចឱ្យមានការរៀបចំកិច្ចប្រជុំចំនួនពីរដងក្នុងមួយឆ្នាំ ដើម្បីត្រួតពិនិត្យមើលលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍ ដោយប្រធានអង្គប្រជុំត្រូវប្តូរវេណគ្នា។ នៅឆ្នាំ២០១១ នេះ កម្ពុជាត្រូវធ្វើជាប្រធានអង្គប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច នៃប្រទេស CLMV ។